ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៧៣ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៦-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤៦ ស្តីពី ការតែងតាំងអគ្គសវនករ១រូប និងអគ្គសវនកររង២រូប នៃអាជ្ញាធរសវនកម្មជាតិ សម្រាប់បន្តអាណត្តិ៥ (ប្រាំ)ឆ្នាំ | ៩០០១ |
| ១៦-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤៧ ស្តីពី ការប្រោសព្រះរាជទាន ចំពោះលោកជំទាវ **ពុំ ចន្ទីនី** នូវគ្រឿងឥស្សរិយយស ជាតូបការ | ៩០០២ |
| ១៧-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤៨ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **លឹម សំណាង** ពីសមាសភាពឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានឋានៈស្មើ រដ្ឋលេខាធិការ | ៩០០៣ |
| ១៧-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **ហួន ច័ន្ទធុន** ជាសមាសភាពឧត្តមក្រុមប្រឹក្សាពិគ្រោះ និងនិងផ្តល់យោបល់ មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | ៩០០៤ |
| ១៧-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៥០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី កញ្ញា ឧបាសក ឧបាសិកា និងព្រះសង្ឃ ចំនួន ៦៩ រូប/អង្គ | ៩០០៥ |
| ១៨-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៥១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលបានទទួលមរណៈភាព ៧ រូប | ៩០០៧ |
| ១៨-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៥២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ លោក **ប៉េ ហ្វ្រង់ស្វ័រ ប៉ុងស្សូ** (**Père François Ponchaud**) | ៩០០៩ |


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ១៦-១២-២០២១ | -អនុក្រឹត្យលេខ ២៤៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៩០១០ |
| ១៧-១២-២០២១ | -អនុក្រឹត្យលេខ ២៤៨ អនក្រ.បក ស្តីពី ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.អ) ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ | ៩០១២ |

២១-១២-២០២១ -អនុក្រឹត្យលេខ ២៥១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩០១៦

២២-១២-២០២១ -អនុក្រឹត្យលេខ ២៥២ អនក្រ.បក ស្តីពី ការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ៩០១៨

២២-១២-២០២១ -អនុក្រឹត្យលេខ ២៥៣ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ៩០២៤

២២-១២-២០២១ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩០៣១

២២-១២-២០២១ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩០៣២

២២-១២-២០២១ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៩០៣៤

២២-១២-២០២១ -អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩០៣៦

២២-១២-២០២១ -អនុក្រឹត្យលេខ ៥៨១ អនក្រ.តត ស្តីពី ការលុបឈ្មោះ នាយទាហាន ៩០៣៨

២២-១២-២០២១ -អនុក្រឹត្យលេខ ៥៨២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩០៣៩

## ២~សេចក្តីសម្រេច

១៦-១២-២០២១ -សេចក្តីសម្រេចលេខ ១២២ សសរ ស្តីពី ការដាក់ឱ្យប្រើប្រាស់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ច កម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣ ៩០៤១

# III~ការងារបណ្តាក្រសួង

## ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៣-៧-២០២១ -សេចក្តីសម្រេចលេខ ០៤០ សហវ ស្តីពី ការបង្កើតក្រុមការងារចំពោះកិច្ចរៀបចំក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពិក្រសួង ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ៩០៤៦

## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១៥-៩-២០២១ -ប្រកាសលេខ ៣២៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខនហ្វីឌល បង្កើតរោងចក្រ ផលិតស្រាទឹកត្នោត-ស្ករត្នោត-ស្ករគ្រាប់-ម្រេចកញ្ចប់-ម្រេចជ្រក់ និងតែ ៩០៥១

១៥-៩-២០២១ -ប្រកាសលេខ ៣២៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ិតធីក អ៊ីឡាយអិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩០៥៤

| | | |
|---|---|---|
| ១៥-៩-២០២១ | -ប្រកាសលេខ ៣២៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាន់កូ អ៊ិនដាសស្ទ្រៀល បង្កើតរោងចក្រ កាត់ដេរ ប៉ាក់ និងបោះពុម្ពសម្លៀកបំពាក់ | ៩០៥៧ |
| ១៥-៩-២០២១ | -ប្រកាសលេខ ៣៣០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុនមីង ហ្វៃ អេនធើប្រាយ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូប **SLIPPER, EYES MARKS,** ស្រោមជើងគ្រប់ប្រភេទ និងសម្ភារៈប្រើប្រាស់ក្នុងសណ្ឋាគារ (**Laundry Bag, Cotton Bag, Facial Cleansing Cloth……**), ក្រណាត់មិនត្បាញគ្រប់ប្រភេទ និងសម្លៀកបំពាក់រក្សាអនាម័យ | ៩០៦០ |
| ១៧-៩-២០២១ | -ប្រកាសលេខ ៣៣១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ទ្រីលាន ហ្គាមេន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៩០៦៣ |
| ១៧-៩-២០២១ | -ប្រកាសលេខ ៣៣២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជុង ហាវ ហ្គាមេន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៩០៦៦ |
| ២០-៩-២០២១ | -ប្រកាសលេខ ៣៣៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ធី.ខេ.ហ្គាមេន ស៊ីសុផុន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៩០៦៩ |
| ២០-៩-២០២១ | -ប្រកាសលេខ ៣៣៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោលដេន ប្រស្ទើរ អេនធើប្រាយ ឯ.ក បង្កើតរោងចក្រ ផលិតអំពូលភ្លើងលំអគ្រប់ប្រភេទ | ៩០៧២ |
| ២០-៩-២០២១ | -ប្រកាសលេខ ៣៣៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សានយ៉ូ ភែកឃិច អេស៊ា (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិត ផលិតផលពីក្រដាស | ៩០៧៥ |
| ២០-៩-២០២១ | -ប្រកាសលេខ ៣៤២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេវើរី ដេននីសាន់ អបឹអាសអេស (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតស្លាកសញ្ញា (សម្លៀកបំពាក់ និងស្បែកជើងគ្រប់ប្រភេទ) | ៩០៧៨ |


## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


| | | |
|---|---|---|
| ១០-១២-២០២០ | -ប្រកាសលេខ ០៦៤៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៦៤៦ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ | ៩០៨១ |
| ១០-១២-២០២០ | -ប្រកាសលេខ ០៦៤៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៦៤៧ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ | ៩០៨៥ |
| ១០-១២-២០២០ | -ប្រកាសលេខ ០៦៤៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៦៤៨ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ | ៩០៨៩ |

១០-១២-២០២០ -ប្រកាសលេខ ០៦៥០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦៥០ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ៩០៩៣
១០-១២-២០២០ -ប្រកាសលេខ ០៦៥២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦៥២ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ៩០៩៧
១០-១២-២០២០ -ប្រកាសលេខ ០៦៥៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៦៥៤ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ៩១០១
១០-១២-២០២០ -ប្រកាសលេខ ០៦៥៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦៥៥ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ៩១០៥
១០-១២-២០២០ -ប្រកាសលេខ ០៦៥៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦៥៦ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ៩១០៩
១០-១២-២០២០ -ប្រកាសលេខ ០៦៥៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦៥៧ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ៩១១៣
១០-១២-២០២០ -ប្រកាសលេខ ០៦៥៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការមណ្ឌល
សន្និធិឧស្ម័ន អិល ភី ជី លេខ ០៦៥៨ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ៩១១៧
១១-១២-២០២០ -ប្រកាសលេខ ០៦៦០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦៦០ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩១២១

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០២១/០១៥ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតទុកចិត្តលើការតែងតាំងអគ្គសវនករចំនួន១រូបនិងអគ្គសវនកររងចំនួន២រូបនៃអាជ្ញាធរសវនកម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងអគ្គសវនករ១រូបនិងអគ្គសវនកររង២រូបនៃអាជ្ញាធរសវនកម្មជាតិ សម្រាប់បន្តអាណត្តិ៥ (ប្រាំ)ឆ្នាំ៖

| | | |
|---|---|---|
| ១-លោកជំទាវ | **សោម គីមសួគ៌** | ជាអគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ |
| ២-ឯកឧត្តម | **សួន សិទ្ធី** | ជាអគ្គសវនកររងនៃអាជ្ញាធរសវនកម្មជាតិ |
| ៣-ឯកឧត្តម | **អ៊ុក សារាវុធ** | ជាអគ្គសវនកររងនៃអាជ្ញាធរសវនកម្មជាតិ។ |

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.១២២១.៩៦៧

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានបង្ហាញជូនគោរពដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៥៤៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោធតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

លោកជំទាវ ពុំ ចន្ទីនី

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ**

ន សីហមុនី

ពរល.២១១៤.៩៦៨

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០២១*

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៨៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១១៨/១៣០១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រា១៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បញ្ចប់មុខតំណែងឯកឧត្តម **លឹម សំណាង** ពីសមាសភាពឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានឋានៈស្មើ **រដ្ឋមន្ត្រី**។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៩៧. ២០១៤. ៨៦៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០២១*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានបម្រុងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/១២២១/៨៤៧

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១១៨/១៣០១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រា១៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងនិងផ្តល់ឋានៈដល់ ឯកឧត្តម **ហួន ច័ន្ទធុន** ជាសមាសភាពឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី**។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

ចារទុក. ២១១២. ៩៧០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានបង្ហាញថាត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៤៥០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

## ដូចៈ

ក- គ្រឿងឥស្សរិយយស **ជាតូបការ :**

១- ព្រះឃោសមុនីវង្ស **ច័ន្ទ ចន្ថោ្ណា**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

| | |
|---|---|
| ១- ព្រះគ្រូ អគ្គប្បសាទញ្ញាណអគ្គវង្សា **ឆាយ អន** | ២- ព្រះពោធិនាគមុនីមេត្តារក្ខិតោ **ឆន ម៉ៅមេត្តា** |
| ៣- លោកជំទាវ **ឈឿន ម៉ារ៉ានី** | ៤- លោក **ផាន់ ញាណចន្ទ** |
| ៥- លោក **កេត សុជាតិ** | ៦- លោក **ហោ គាឡេង** |
| ៧- លោក **ខុធ ហាឡម្ហែន** | ៨- លោក **ផន ច័ន្ទតុលា** |
| ៩- លោក **ទ៉ា ទ៉ាន់ខូច** | ១០- លោក **ម្ឿង ព្រីក្សា** |
| ១១- លោក **គឹម ប៊ុនលីកន** | ១២- លោក **ហ៊ី សាម្មីឌី** |
| ១៣- លោក **ប៉ាង សុវណ្ណា** | ១៤- លោក **អឿ សុគា** |
| ១៥- លោក **ជី អេន** | ១៦- លោក **ឡុង ប៊ុនហួរ** |
| ១៧- លោក **ធេស សត្ថា** | ១៨- លោក **អ៊ុងតួង សម្បត្តិតារា** |
| ១៩- លោក **ចាំង ឬទ្ធី** | ២០- ឯកឧត្តមបណ្ឌិត **ស៊ីសុវត្ថិ ចក្រីទុពល** |
| ២១- លោក **គង់ លីទ៉ា** | ២២- លោក **កែវ ផុង** |

គ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

| | |
|---|---|
| ១- លោកជំទាវ **ឈាង ថាវរី** | ២- លោក **គង់ ថុ** |
| ៣- លោក **សែម សុគា** | ៤- លោកស្រី **តាក វណ្ណសៅនីតា** |
| ៥- លោកស្រី **សែម សម្បត្តិ** | ៦- លោកជំទាវ **ហួត រដ្ឋា** |
| ៧- លោក **ផុន តារិទ្ធ** | ៨- លោក **លី ស៊ី** |
| ៩- លោក **គល់ យី** | |

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

| | |
|---|---|
| ១- ឯកឧត្តម **ជា សុភ័ក្រ** | ២- ឯកឧត្តម **អ៊ុកចាយ បញ្ញារ៉ា** |
| ៣- លោក **សែម រមនា** | ៤- លោក **ពេជ្រ សំបូរ** |
| ៥- លោក **ឡុង ចាន់សាសនា** | ៦- លោក **សុខ ឡុងឌី** |
| ៧- លោក **ផុន សុផាន់ណារិទ្ធ** | ៨- លោក **គ្រុយ គីមលន** |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៩- លោកស្រី **តាក់ សុខណា** ១០- កញ្ញា **ជី ស្រីណុច**
១១- លោក **តុល សំអន** ១២- លោកស្រី **សយ ធណ្ណៈ**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា :**

១- លោក **ហ៊ាន ណារដ្ឋ** ២- លោក **សារ៉េន ច័ន្ទមករា**
៣- លោក **អ៊ី ស៊ុនហេង** ៤- លោក **ហ៊ុយ ខេមរា**
៥- លោក **ឯក ផល្លា** ៦- លោក **ឆៃ បុណា**
៧- លោក **ពេជ្រ រ៉ា** ៨- លោកស្រី **អាង ស្រីណែត**
៩- លោក **សែ ឲ្យារេត** ១០- លោក **ម៉ៅ តកយាន**

ច- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា :**

១- ឧបាសិកា **ឈួន ណាត** ២- ឧបាសក **ញ៉េស ជួន**
៣- ឧបាសិកា **នេត យន** ៤- ឧបាសក **អ៊ុម សុមេធ**
៥- Mr.TRAN VIET TRUONG ៦- Mr. LAM MINH HONG
៧- MINGYI MASTER XU JIN CHENG ៨- លោកគ្រូ **ឌុំម សុខរៀង**
៩- លោកស្រី **អ៊ឹង អ៊ីធឌី**

ឆ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ :**

១- លោក **ហឿ ម៉ុនលី** ២- លោក **សៀ ពិសិដ្ឋ**
៣- លោកស្រី **អន សុម៉ាលី** ៤- លោក **អន សុចិត្រា**
៥- លោក **សៅ សារ៉ន** ៦- លោក **អ៊ឹង ហុកណាយ**

នស/រកត.២១១២.៥៧១

នរោត្ដម សីហមុនី

**នរោត្ដម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៤៥១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ យោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ចំពោះ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលបានទទួលមរណភាព ០៧ រូប ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក** :

១-ឧត្តមសេនីយ៍ទោ **ពេជ្រ** **ចន្ថា** អត្តលេខ ០០៣២២៨

២-ឧត្តមសេនីយ៍ទោ **មាស** **ចន្នី** អត្តលេខ ០១៣៩៩៦

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**:

១-ឧត្តមសេនីយ៍ត្រី **សេន** **មុន្នី** អត្តលេខ ០០១៦៨១

២-ឧត្តមសេនីយ៍ត្រី **ឃុ** **ទិបុល** អត្តលេខ ០២៧១២៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**គ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី :**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **សេង** | **ឌង់** | អត្តលេខ ០០១៦៧០ |
| ២-វរសេនីយ៍ឯក | **ឃូ** | **ហ៊ាងឌុង** | អត្តលេខ ០១៣៨៣៩ |
| ៣-វរសេនីយ៍ឯក | **អ៊ុក** | **ឡាយ** | អត្តលេខ ០៩១៦៥៦ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

ចាក់ស.១២១២.៤៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/១២២១/៨៥៦

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

ចំពោះ

លោក **ប៉ែរ ហ្វ្រង់ស័រ ប៉ុងស្សូ** (Père François Ponchaud)

ពាសល.ម១១២.៨៧៣

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៤៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១ ២៧៨ ៩០០ ០០០ រៀល (មួយប៊ីលានពីររយចិតសិបប្រាំបីលានប្រាំបួនរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងព្រះបរមរាជវាំង សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ជម្រះថវិកាបុរេប្រទានចំណាយក្នុងឱកាស **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គស្តេចយាងចូលរួមក្នុងពិធីបើកសម័យប្រជុំមហាសន្និបាតលើកទី ៤១ ក្នុងឱកាសបុណ្យខួបទី ៧៥ នៃអង្គការយូណេស្កូនៅប្រទេសបារាំង។

**មាត្រា៣ .-**

រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៤៨.អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.អ)**

**ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា ១._**

ត្រូវបានបង្កើត **គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត** អក្សរកាត់ « គ.ស.អ » ក្នុងយុទ្ធនាការការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ ដែលសមាសភាពមានដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. សម្តេចក្រឡាហោម | **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២. សម្តេចពិជ័យសេនា | **ទៀ បាញ់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |



ᕤ

៣. ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៥. ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៦. ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៧. ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក

៨. ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សមាជិក

៩. ឯកឧត្តម **សុខ ចិន្តាសោភា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១០.ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១១.ឯកឧត្តមសន្តិបណ្ឌិត **តេង សាវង្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១២.ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៣.ឯកឧត្តម **ម៉ិន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៤.ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៥.ឯកឧត្តមសន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៦.ឯកឧត្តមសន្តិបណ្ឌិត **សុខ ផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៧.ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

១៨.ឯកឧត្តមនាយឧត្តមសេនីយ៍ **វង្ស ពិសេន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

១៩.ឯកឧត្តមនាយឧត្តមសេនីយ៍ **គង់ សុខន** អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក

២០.ឯកឧត្តមនាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សមាជិក

២១.ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២២.ឯកឧត្តមនាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ សមាជិក

២៣.ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ិន ម៉ាំណែត** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក សមាជិក

២៤.**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត** សមាជិក

**មាត្រា ២._**

**គ.ស.អ** មានតួនាទី និងភារកិច្ច ដូចតទៅ ៖

-តាមដាន ត្រួតពិនិត្យ រៀបចំ គ្រប់គ្រង និងប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ធានាឲ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ

២០២២ ដល់ឆ្នាំ២០២៤ តាមនីតិកាល និងអាណត្តិនីមួយៗ ប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព គ្មានការភ័យខ្លាច ការបំភិតបំភ័យ ការគម្រាមកំហែង និងគ្មានអំពើហិង្សាផ្សេងៗ

-ធ្វើការពិគ្រោះយោបល់ និងចាត់ចែងផ្តល់កិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម រួមទាំងវិស័យការងារផ្សេងៗទៀត តាមសំណើរបស់ **គ.ជ.ប** ឬ/និង **គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់** ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ពិសេសច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ **គ.ជ.ប** ផែនការអន្តរស្ថាប័នរបស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង **គ.ជ.ប** ក្រមសីលធម៌ និងសេចក្តីណែនាំពាក់ព័ន្ធផ្សេងៗទៀត

-ចាត់ចែងគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស សម្ភារ ឧបករណ៍បច្ចេកទេស និងមធ្យោបាយគ្រប់ប្រភេទរបស់ក្រសួង/ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដែលមានស្រាប់ ក្នុងទិសដៅជំរុញយុទ្ធនាការការពារការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោត ឲ្យទទួលបានជោគជ័យ

-ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងអប់រំផ្សព្វផ្សាយគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់គ្រប់យន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោត ឲ្យបានជ្រួតជ្រាប និងដើម្បីសហការអនុវត្តជានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសម្រាប់ការបោះឆ្នោតឲ្យមានលក្ខណៈកាន់តែប្រសើរឡើង ប្រកបដោយការទទួលខុសត្រូវខ្ពស់

-លើកគម្រោងស្នើថវិកាបំប៉នដល់គ្រប់យន្តការ រចនាសម្ព័ន្ធ និងភ្នាក់ងារសន្តិសុខបោះឆ្នោត និងគម្រោងថវិកាសម្រាប់ការផ្គត់ផ្គង់ជាសម្ភារ មធ្យោបាយ ប្រេងឥន្ធនៈ ការបណ្តុះបណ្តាល និងការចំណាយចាំបាច់ផ្សេងៗទៀត បម្រើដល់កិច្ចប្រតិបត្តិការការពារយុទ្ធនាការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតនីមួយៗ ដាក់ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងអនុម័ត។

**មាត្រា ៣._**

**គ.ស.អ** មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ហើយមានលេខាធិការដ្ឋានមួយជាសេនាធិការ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលសមាសភាព និងតួនាទីភារកិច្ចរបស់លេខាធិការដ្ឋាននេះ នឹងត្រូវកំណត់តាមសេចក្តីសម្រេចរបស់ប្រធាន **គ.ស.អ** ។

អនុប្រធាន និងសមាជិករបស់ **គ.ស.អ** ត្រូវចូលរួមគ្រប់កិច្ចប្រជុំទាំងអស់ តាមការអញ្ជើញរបស់ប្រធាន **គ.ស.អ** ។

**មាត្រា ៤._**

គណៈអភិបាលរាជធានី ខេត្ត និងជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តដែលមានស្រាប់ ត្រូវបានកំណត់ជាស្វ័យប្រវត្តិជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រងដឹកនាំបញ្ជា និងត្រួតពិនិត្យលើការអនុវត្តរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរៀងៗខ្លួន។ កម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ដែលមានមូលដ្ឋានឈរជើងក្នុងភូមិសាស្ត្ររាជធានី ខេត្តនីមួយៗ ត្រូវរៀបចំឲ្យបំពេញភារកិច្ចជា **ភ្នាក់ងារសន្តិសុខបោះឆ្នោត** ផ្អែកតាមផែនការដែលបានកំណត់។

**មាត្រា ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។



αß

មាត្រា ៦._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គស្នងការនគរបាលជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំង សមាសភាពដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលបន្ទុកអនុវត្តការកិច្ចតាមសមត្ថកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃ សុក្រ ១៣ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>** ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១២៩១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃចន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ១៨៧ អនក្រ.បក ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២១
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ក្នុងជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) លើកទី៣ ចំនួន ១០៤ ៥០០ លានរៀល ពីខ្ទង់ឥណទានថវិកាមិនទាន់បែងចែកអចលកម្មរូបី ជូនក្រសួងចំនួន ៤ ដូចខាងក្រោម÷

| | |
|---|---|
| -ក្រសួងមហាផ្ទៃ | ចំនួន ៤ ៥០០ លានរៀល |
| -ក្រសួងអប់រំ យុវជន និងកីឡា | ចំនួន ៣០ ០០០ លានរៀល |
| -ក្រសួងអភិវឌ្ឍន៍ជនបទ | ចំនួន ៤០ ០០០ លានរៀល |
| -ក្រសួងសាធារណការ និងដឹកជញ្ជូន | ចំនួន ៣០ ០០០ លានរៀល |

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ថ្ងៃអង្គារ ១២កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ២.៥២.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីសៀវភៅស្នាក់នៅ
- បានឃើញអនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីសៀវភៅគ្រួសារ
- បានឃើញអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

អនុក្រឹត្យនេះកំណត់អំពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ក្នុងគោលបំណងធានាការពារសន្តិសុខ សណ្តាប់ធ្នាប់ ផលប្រយោជន៍សាធារណៈ លើកកម្ពស់គុណភាពនៃការផ្តល់សេវានានា និងអភិវឌ្ឍជាតិ ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់។

**មាត្រា២._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣._**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យដូចតទៅ៖

- **ទិន្នន័យអត្តសញ្ញាណបុគ្គល** សំដៅដល់ព័ត៌មាននានា ដែលអាចកំណត់បានអត្តសញ្ញាណបុគ្គលណាម្នាក់។ ទិន្នន័យអត្តសញ្ញាណបុគ្គលអាចជាទិន្នន័យអំពីឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ទីលំនៅបច្ចុប្បន្ន ជនជាតិ សញ្ជាតិ រួមទាំងទិន្នន័យជីវមាត្រ ឬទិន្នន័យផ្សេងទៀត ដែលទាក់ទងនឹងអត្តសញ្ញាណរបស់បុគ្គល។
- **ព័ត៌មានឯកជនរបស់បុគ្គល** សំដៅដល់បន្សំនៃទិន្នន័យដែលអាចឱ្យដឹងបានអំពីព័ត៌មានជីវភាពឯកជន ឬការសម្ងាត់របស់បុគ្គលណាម្នាក់។

## ជំពូកទី២
## សមត្ថកិច្ចក្នុងការគ្រប់គ្រងទិន្នន័យអត្តសញ្ញាណបុគ្គល

**មាត្រា៤._**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចក្នុងការប្រមូល ចងក្រង រក្សាទុក គ្រប់គ្រង និងការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ដែលបានមកពីការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ស្ថិតិនិងគ្រប់គ្រងការស្នាក់នៅ លិខិតឆ្លងដែន សញ្ជាតិ និងការចុះបញ្ជីផ្សេងទៀត ដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តប្រគល់ឱ្យក្រសួងមហាផ្ទៃ។

ក្រសួងមហាផ្ទៃដែលជាម្ចាស់ទិន្នន័យដើមអាចអនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាពទាំងវិស័យសាធារណៈ និងវិស័យឯកជន ឬបុគ្គល ប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គលបាន ស្របតាមបែបបទ និងនីតិវិធី ដែលកំណត់ក្នុងអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា៥._**

ក្រសួងមហាផ្ទៃអាចកែតម្រូវទិន្នន័យអត្តសញ្ញាណបុគ្គល ដែលបានមកពីប្រភពនានា ដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ ស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៣
## គោលការណ៍នៃការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល

**មាត្រា៦._**

អនុញ្ញាតឱ្យប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល ដែលបានរក្សាទុក និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ក្នុងគោលបំណងផ្ទៀងផ្ទាត់ ឬបញ្ជាក់អំពីភាពត្រឹមត្រូវ ឬបញ្ជាក់អំពីអត្តសញ្ញាណបុគ្គល ដើម្បីបម្រើផលប្រយោជន៍សាធារណៈ លើកកម្ពស់គុណភាពនៃការផ្ដល់សេវា និងការអភិវឌ្ឍជាតិ។

**មាត្រា៧._**

ក្រសួង ស្ថាប័ន អង្គភាពទាំងវិស័យសាធារណៈ និងវិស័យឯកជន ឬបុគ្គលដែលមានបំណងប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ស្របទៅតាមបែបបទ នីតិវិធី និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៨._**

ការអនុញ្ញាតឱ្យក្រសួង ស្ថាប័នក្នុងវិស័យសាធារណៈ ប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល ដើម្បីបម្រើឱ្យការផ្ដល់សេវាសាធារណៈ ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួង ឬប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នដែលស្នើសុំ។

ការអនុញ្ញាតឱ្យស្ថាប័ន អង្គភាព ក្នុងវិស័យឯកជន ប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល ដើម្បីបម្រើឱ្យការផ្ដល់សេវាសាធារណៈ ត្រូវធ្វើឡើងដោយកិច្ចព្រមព្រៀង ឬអនុស្សរណៈយោគយល់គ្នារវាងតំណាងក្រសួងមហាផ្ទៃ និងប្រធាន ឬតំណាងស្ថាប័ន អង្គភាព ក្នុងវិស័យឯកជនដែលស្នើសុំ។

បែបបទ និងនីតិវិធីនៃការស្នើសុំបញ្ជាក់អំពីអត្តសញ្ញាណបុគ្គល ឬបញ្ជាក់អំពីភាពត្រឹមត្រូវ ដែលស្នើសុំដោយសាមីខ្លួន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បែបបទ និងនីតិវិធីនៃការស្នើសុំបញ្ជាក់អំពីអត្តសញ្ញាណបុគ្គល ឬបញ្ជាក់អំពីភាពត្រឹមត្រូវ ដើម្បីប្រើប្រាស់នៅក្នុងវិស័យយុត្តិធម៌ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៩._**

ការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល ត្រូវធានារក្សាការពារការសម្ងាត់នៃព័ត៌មានឯកជនរបស់បុគ្គល សុវត្ថិភាព ភាពត្រឹមត្រូវ និងសុចរិតភាព។

**មាត្រា១០.-**

ក្រសួងមហាផ្ទៃដែលជាម្ចាស់ទិន្នន័យដើម ត្រូវធានាថារាល់ទិន្នន័យអត្តសញ្ញាណបុគ្គល មានភាពត្រឹមត្រូវ ដែលអាចធ្វើជាមូលដ្ឋានក្នុងការផ្ទៀតផ្ទាត់ និងប្រើប្រាស់ជាផ្លូវការបាន។

ករណីមានការកែតម្រូវទិន្នន័យអត្តសញ្ញាណបុគ្គលណាមួយ ដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ ក្រសួងមហាផ្ទៃត្រូវធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួន ស្របតាមបែបបទ និងនីតិវិធីជាធរមាន។

**មាត្រា១១.-**

ក្រសួង ស្ថាប័ន អង្គភាពទាំងវិស័យសាធារណៈ និងវិស័យឯកជន ដែលស្នើសុំប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណបុគ្គល ត្រូវធានាថាទិន្នន័យដែលបានប្រើប្រាស់រួច មិនត្រូវបានរក្សាទុកក្នុងប្រព័ន្ធរបស់ខ្លួន និង មិនត្រូវចែករំលែកទិន្នន័យបន្តទៅភាគីផ្សេងទៀត ឬប្រើប្រាស់ទិន្នន័យប្រាសចាកពីគោលបំណងនៃការស្នើសុំ និងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឡើយ។

**មាត្រា១២.-**

ក្រសួងមហាផ្ទៃអាចយកកម្រៃសេវារដ្ឋបាល រាល់ប្រតិបត្តិការនៃការប្រើប្រាស់ ឬការបញ្ជាក់ទិន្នន័យ អត្តសញ្ញាណបុគ្គលពីក្រសួង ស្ថាប័ន អង្គភាពទាំងវិស័យសាធារណៈ និងវិស័យឯកជន ឬសាមីខ្លួនដែលស្នើសុំ។

កម្រៃសេវារដ្ឋបាលនៃការប្រើប្រាស់ ឬការបញ្ជាក់ទិន្នន័យអត្តសញ្ញាណបុគ្គល ត្រូវកំណត់ដោយប្រកាស អន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល

**មាត្រា១៣.-**

ក្រសួងមហាផ្ទៃត្រូវការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់ខ្លួន ប្រឆាំងនឹងហានិភ័យ និងគ្រោះថ្នាក់នានា ដូចជាការបំផ្លាញទិន្នន័យ ការខូចខាតឬបាត់បង់ទិន្នន័យ ការលុបចោលទិន្នន័យ ការកែតម្រូវទិន្នន័យ ឬការចូលប្រើប្រាស់ទិន្នន័យដោយគ្មានការអនុញ្ញាត ឬការបង្ហាញ ទិន្នន័យជាសាធារណៈ។

ក្រសួងមហាផ្ទៃត្រូវបង្កើតឱ្យមានប្រព័ន្ធរក្សាទុកទិន្នន័យបម្រុង នៅទីកន្លែងសុវត្ថិភាពផ្សេងពីទីកន្លែង ដែលរក្សាទុកប្រព័ន្ធទិន្នន័យដើម និងរៀបចំថែទាំឱ្យបានត្រឹមត្រូវ។

**មាត្រា១៤.-**

ក្រសួងមហាផ្ទៃដែលជាម្ចាស់ទិន្នន័យដើម និងក្រសួង ស្ថាប័ន អង្គភាពទាំងវិស័យសាធារណៈ និងវិស័យ ឯកជន ដែលជាអ្នកប្រើប្រាស់ទិន្នន័យ ត្រូវធានារក្សាការពារសុវត្ថិភាពទិន្នន័យទាំងក្នុងអំឡុងពេលបញ្ជូន និង ពេលប្រើប្រាស់ដោយអនុវត្តតាមលក្ខខណ្ឌបច្ចេកទេសសុវត្ថិភាពខ្ពស់។

**មាត្រា១៥._**

ក្រសួង ស្ថាប័ន អង្គភាពទាំងវិស័យសាធារណៈ និងវិស័យឯកជន ដែលជាអ្នកប្រើប្រាស់ទិន្នន័យ ត្រូវធានារក្សាការពារសុវត្ថិភាពទិន្នន័យក្រោយពេលប្រើប្រាស់រួច ដោយអនុវត្តតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាពខ្ពស់បំផុត។

រាល់ទិន្នន័យដែលបានប្រើប្រាស់ ឬបញ្ជូនឱ្យប្រើប្រាស់រួច នៅតែជាទិន្នន័យរបស់ក្រសួងមហាផ្ទៃ ទោះបីជាក្រសួង ស្ថាប័ន អង្គភាពទាំងវិស័យសាធារណៈ និងវិស័យឯកជន បានប្រើប្រាស់ទិន្នន័យទាំងនោះក្នុងរូបភាពណាក៏ដោយ។

**មាត្រា១៦._**

បែបបទ នីតិវិធី និងលក្ខខណ្ឌបច្ចេកទេសនៃការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**មាត្រា១៧._**

បុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក្រសួងមហាផ្ទៃអាចសម្រេចដាក់ទណ្ឌកម្មខាងវិន័យណាមួយដូចខាងក្រោម៖

ក- ការព្រមាន

ខ- ការស្តីបន្ទោស

គ- ការដាក់កំហិត ការព្យួរ ឬលុបចោលកិច្ចព្រមព្រៀង ឬអនុស្សរណៈយោគយល់គ្នា។

**មាត្រា១៨._**

ការអនុវត្តទោសប្បញ្ញត្តិក្នុងជំពូកទី៥នៃអនុក្រឹត្យនេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតឡើយ ក្នុងករណីដែលការបំពានលើបទប្បញ្ញត្តិមានចែងក្នុងអនុក្រឹត្យនេះ ជាបទល្មើសព្រហ្មទណ្ឌដែលបានបញ្ញត្តក្នុងច្បាប់ជាធរមាន។

**មាត្រា១៩._**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចខុសពីគោលបំណងនៃអនុក្រឹត្យនេះ ឬប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
**សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៥៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃ ពុធ ១១កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

ឥណទានចំណូលថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដែលមានប្រភពចំណូល និងតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដូចមានក្នុងតារាងភ្ជាប់ជាមួយអនុក្រឹត្យនេះ។

**មាត្រា២.-**

ចំណូលទាំងអស់នេះ ត្រូវប្រមូលដើម្បីគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិ និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការបែងចែកឥណទានចំណូលនៃជំពូកទាំងនេះតាមគណនី និងអនុគណនី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីដែលជាប្រធានក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# តារាងបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | **០១-ព្រះបរមរាជវាំង** | **2.075,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 2.075,0 |
| | **០៥-គណៈរដ្ឋមន្ត្រី** | **151.101,3** |
| | **ផ្នែក១-ទីស្តីការគណៈរដ្ឋមន្ត្រី** | **90.000,0** |
| 75 | ការឧបត្ថម្ភ អំណោយ | 90.000,0 |
| | **ផ្នែក៣-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** | **47.595,3** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 47.595,3 |
| | **ផ្នែក៤-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** | **13.506,0** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 8.506,0 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 5.000,0 |
| | **០៦-ក្រសួងការពារជាតិ** | **439,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 439,0 |
| | **០៧-ក្រសួងមហាផ្ទៃ** | **379.383,3** |
| | **ផ្នែក១-សន្តិសុខសាធារណៈ** | **373.703,1** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 323.980,8 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 49.687,9 |
| 77 | ផលផ្សេងៗនិងផលពិសេស | 34,4 |
| | **ផ្នែក៩-សាលារាជធានី ខេត្ត** | **5.680,2** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 5.680,2 |
| | **០៩-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** | **65.325,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 65.325,0 |
| | **១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **29.039.218,4** |
| | **ផ្នែក១-អគ្គនាយកដ្ឋានគយនិងរដ្ឋាករ** | **10.481.405,0** |
| 70 | ចំណូលសារពើពន្ធក្នុងស្រុក | 7.988.300,0 |
| 71 | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.411.705,0 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 81.400,0 |
| | **ផ្នែក២-អគ្គនាយកដ្ឋានពន្ធដារ** | **9.835.000,0** |
| 70 | ចំណូលសារពើពន្ធក្នុងស្រុក | 9.827.000,0 |

# តារាងបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូក
# នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 8.000,0 |
| | **ផ្នែក៣-ទីស្តីការក្រសួង** | **8.722.411,4** |
| | -ចំណូលចរន្ត | **335.388,4** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 162.060,4 |
| 76 | ផលហិរញ្ញវត្ថុ | 173.328,0 |
| | -ចំណូលមូលធន | **8.387.023,0** |
| 27 | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 85.759,0 |
| 75 | ការឧបត្ថម្ភ អំណោយ | 876.206,0 |
| 50 | ការខ្ចីប្រាក់និងបំណុលប្រហាក់ប្រហែល | 7.425.058,0 |
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | **402,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 402,0 |
| | **១១-ក្រសួងព័ត៌មាន** | **1.779,1** |
| | **ផ្នែក១-ក្រសួង** | **1.779,1** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.779,1 |
| | **១២-ក្រសួងសុខាភិបាល** | **10.924,4** |
| | **ផ្នែក១-ក្រសួង** | **10.924,4** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 10.670,0 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 254,4 |
| | **១៣-ក្រសួងរ៉ែនិងថាមពល** | **143.198,5** |
| | **ផ្នែក១-ក្រសួង** | **31.345,5** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 25.072,0 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 5.873,5 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 400,0 |
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | **111.853,0** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 111.853,0 |
| | **១៥-ក្រសួងពាណិជ្ជកម្ម** | **51.163,7** |
| | **ផ្នែក១-ក្រសួង** | **50.522,2** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 48.322,2 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 2.200,0 |

# តារាងបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | **641,5** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 641,5 |
| | **១៦-ក្រសួងអប់រំ យុវជន និងកីឡា** | **3.122,9** |
| | **ផ្នែក១-អប់រំ** | **3.122,9** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 550,0 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 2.572,9 |
| | **១៧-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **37.144,8** |
| | **ផ្នែក១-ក្រសួង** | **37.143,4** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 20.992,0 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 12.831,4 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 3.320,0 |
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | **1,4** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1,4 |
| | **១៨-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** | **4.217,2** |
| | **ផ្នែក១-ក្រសួង** | **4.173,6** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 4.173,6 |
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | **43,6** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 43,6 |
| | **១៩-ក្រសួងបរិស្ថាន** | **11.952,7** |
| | **ផ្នែក១-ក្រសួង** | **11.952,7** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 9.277,7 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 420,0 |
| 75 | ការឧបត្ថម្ភ អំណោយ | 2.255,0 |
| | **២១-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **24,0** |
| | **ផ្នែក១-ក្រសួង** | **24,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 24,0 |
| | **២២-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** | **399.304,0** |
| | **ផ្នែក១-ក្រសួង** | **399.304,0** |

# តារាងបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូក
# នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 399.204,0 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 100,0 |
| | **២៥-ក្រសួងសាធារណការនិងដឹកជញ្ជូន** | **36.217,9** |
| | **ផ្នែក១-ក្រសួង** | **36.212,9** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 6.980,0 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 21.547,9 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 7.685,0 |
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | **5,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 5,0 |
| | **២៦-ក្រសួងយុត្តិធម៌** | **9.180,0** |
| | **ផ្នែក១-យុត្តិធម៌** | **2.709,6** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 2.709,6 |
| | **ផ្នែក២-តុលាការកំពូល** | **767,5** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 767,5 |
| | **ផ្នែក៣-សាលាឧទ្ធរណ៍** | **1.468,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.468,0 |
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | **4.234,9** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 2.766,9 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 1.468,0 |
| | **២៧-ក្រសួងទេសចរណ៍** | **104.689,4** |
| | **ផ្នែក១-ក្រសួង** | **104.668,4** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 104.648,4 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 20,0 |
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | **21,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 21,0 |
| | **២៨-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | **15.530,0** |
| | **ផ្នែក១-ក្រសួង** | **15.530,0** |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 15.530,0 |

# តារាងបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូក
# នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | **៣២-ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** | 64.973,5 |
| | **ផ្នែក១-ក្រសួង** | 64.973,5 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 64.913,5 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 60,0 |
| | **៣៥-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | 13.401,9 |
| | **ផ្នែក១-ក្រសួង** | 13.322,2 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 13.166,2 |
| 74 | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 150,0 |
| 77 | ផលផ្សេងៗនិងផលពិសេស | 6,0 |
| | **ផ្នែក៩-មន្ទីរជំនាញរាជធានី ខេត្ត** | 79,7 |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 79,7 |
| | **សរុបចំណូលចរន្ត** | 22.157.343,0 |
| | **ក្រសួង** | 22.034.380,7 |
| | **មន្ទីរជំនាញរាជធានី ខេត្ត** | 122.962,3 |
| | **សរុបចំណូលមូលធន** | 8.387.023,0 |
| | **សរុបចំណូលថវិកាថ្នាក់ជាតិ** | 30.544.366,0 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៩៧៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា១.**បំពាក់មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់**ធិបឌិន្ទ** ប្រគេន និងជូនសប្បុរសជនចំនួន៣រូប ដែលបានបរិច្ចាគបច្ច័យ និងធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តព្រៃផ្តៅ ឃុំរំចេក ស្រុកព្រះស្តេច ខេត្តព្រៃវែង ចំណាយអស់ថវិកាសរុបចំនួន ១៦៨ ៩៦៦ (មួយរយហុកសិបប្រាំបីពាន់ ប្រាំបួនរយហុកសិបប្រាំមួយ)ដុល្លារអាម៉េរិក កន្លងមកដូចមានរាយព្រះនាម និងនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | **មៅ ឡាប់** | ព្រះចៅអធិការវត្តព្រៃផ្តៅ |
| ២- | ឧបាសក | **ទូច សាវ៉ៃ** | |
| ៣- | លោកស្រី | **ពិន សុខន** | |

**មាត្រា២.**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ព្រហ ៣ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥៧៨ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១.** បំពាក់មេដាយ**មាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជនចំនួន១៨រូប ដែលបានបរិច្ចាគបច្ច័យ និងធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តព្រៃផ្តៅ ឃុំរំចេក ស្រុកព្រះស្តេច ខេត្តព្រៃវែង ចំណាយអស់ថវិកាសរុបចំនួន ២២៤ ៩០៩ (ពីររយម្ភៃបួនពាន់ប្រាំបួនរយកៅសិបប្រាំបួន)ដុល្លារអាម៉េរិក កន្លងមកដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- | ព្រះតេជគុណ | សូ ឈឹម |
| ២- | ព្រះតេជគុណ | ស៊ុយ វី |
| ៣- | ព្រះតេជគុណ | ឌុល ឆុន |
| ៤- | ឧបាសិកា | ស្បោង សឿន |
| ៥- | ឧបាសក | ណឹម បាន |
| ៦- | ឧបាសក | ទៀង សារ៉ាត់ |
| ៧- | ឧបាសក | ជឹម ឡាង |
| ៨- | ឧបាសក | ពោច ជន |

៩- ឧបាសក ខៀវ នន់
១០- ឧបាសក ជើង រី
១១- ឧបាសក ស៊ីន ភួង
១២- ឧបាសក ពិន រ៉េត
១៣- ឧបាសក ចិន ស៊ាត
១៤- ឧបាសក យុត ភន់
១៥- ឧបាសក ម៉ែន សុខ
១៦- លោក អាត់ វីន
១៧- លោក ឡុក អ៊ុន
១៨- លោក តែប គុន

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ៣ រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧៦៩ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ០២រូប នៅក្នុងខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមៈ

១-លោក **យឹម សារិន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ពីអភិបាល នៃគណៈអភិបាលស្រុកបរិបូណ៌ ឱ្យទៅបម្រើការងារនៅរដ្ឋបាលខេត្តកំពង់ឆ្នាំង

២-លោក **ហៃ មនោរម្យ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ពីអភិបាល នៃគណៈអភិបាលស្រុកជលគិរី ឱ្យទៅបម្រើការងារនៅរដ្ឋបាលខេត្តកំពង់ឆ្នាំង។

**មាត្រា ២ :** តែងតាំងមន្ត្រីរាជការចំនួន ០៣រូប ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុក នៅក្នុងខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមៈ

១-លោក **ចេង ចាន់ដួណា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកបរិបូណ៌

២-លោក **យ៉ែម លក្ខិណា** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ២ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកកំពង់លែង

៣-លោក **ដួង គីមស៊ីន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកជលគិរី ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៣ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៨០ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំងមន្ត្រីរាជការចំនួន ០៣ រូប របស់ក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម៖

១-លោក **សេង ហុង** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ជំនួសលោក **ហុង បញ្ញាវិទ្ធ** ដែលបានទទួលភារកិច្ចថ្មី

២-លោក **យ៉ែម សុផល** ជាប្រធាននាយកដ្ឋានអធិការកិច្ចរដ្ឋបាល និងទទួលពាក្យបណ្តឹង នៃអគ្គាធិការដ្ឋាន

៣-លោក **ឌិត សីច័ន្ទលី** ជាប្រធាននាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៩៥៧.១.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការលុបឈ្មោះ នាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** លុបឈ្មោះនាយទាហានចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ចំពោះ វរសេនីយ៍ឯក **ចាន់ ធី** អត្តលេខ ០០៨៤៩៤ នាយរង ការិយាល័យបច្ចេកទេស នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ ក្រសួងការពារជាតិ ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ព្រហស្បតិ៍ ៣ រោច ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្ដីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាល នៃគណៈអភិបាលក្រុង ស្រុក នៅខេត្តកោះកុង សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម៖

១-លោក **ឈេង សុវណ្ណដា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ជាអភិបាល នៃគណៈអភិបាលក្រុងខេមរភូមិន្ទ

២-លោក **អន សុធារិទ្ធ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ជាអភិបាល នៃគណៈអភិបាលស្រុកថ្មបាំង។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២២ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការដាក់ឱ្យប្រើប្រាស់នូវក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវ «ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣» ដែលជាឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<ins>កន្លែងទទួល៖</ins>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣

រៀបចំដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខែ ធ្នូ ឆ្នាំ ២០២១

# អារម្ភកថា

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ, ស្ថិតនៅក្រោមដំបូលនៃសន្តិភាព និង ស្ថិរភាពពេញលេញ, រាជរដ្ឋាភិបាលបានដាក់ចេញ និង អនុវត្តជាបន្តបន្ទាប់ នូវ **យុទ្ធសាស្ត្រចតុកោណ** និង កម្មវិធីកែទម្រង់សំខាន់ៗ ព្រមទាំងបានបង្កើនចំណាយសាធារណៈយ៉ាងច្រើន សំដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមជាតិទាំងមូល ។ ជាលទ្ធផល, កម្ពុជាសម្រេចបានកំណើនខ្ពស់ ដែលបានចូលរួមយ៉ាងខ្លាំងក្លាគួរជាទីមោទនៈ ក្នុងការបង្កើតការងារ និង ការកាត់បន្ថយអាត្រានៃភាពក្រីក្រ ជាពិសេសការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ។ យ៉ាងណាមិញ, ក្នុងឆ្នាំ ២០២០, ពិភពលោកបានជួបនឹងព្រឹត្តិការណ៍ដ៏អាក្រក់មួយ ដែលបង្កជាបច្ច័យអវិជ្ជមានពុំធ្លាប់មានពីមុនមក, ទាំងចំពោះសុខភាពសាធារណៈ និង សង្គម-សេដ្ឋកិច្ច, ពោលគឺ វិបត្តិជំងឺកូវីដ-១៩ ។ អស់រយៈពេលជិត ២ ឆ្នាំកន្លងទៅ, វិបត្តិនេះ បានឆក់យកអាយុជីវិតមនុស្សរាប់លាននាក់ និង បានរុញច្រានសេដ្ឋកិច្ចសកល ឱ្យធ្លាក់ក្នុងវិបត្តិ និង ចោទជាបញ្ហាប្រឈមទៅលើគន្លងនៃការអភិវឌ្ឍរយៈពេលវែង, ទាំងក្នុងក្របខណ្ឌសកល, តំបន់, និង ប្រទេសនីមួយៗ ។

ជាមួយនឹងវឌ្ឍនភាពល្អប្រសើរក្នុងការផលិត និង ការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ ទូទាំងសកល-លោក, ប្រទេសភាគច្រើន បាន និង កំពុងចាត់ទុកវ៉ាក់សាំងជាយុទ្ធសាស្ត្រគន្លឹះ សម្រាប់បើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ច និង គិតគូរជំរុញការស្តារ និង លើកស្ទួយសេដ្ឋកិច្ចឡើងវិញ ។ ទោះជាយ៉ាងនេះក្តី, រហូតមកដល់បច្ចុប្បន្ន, វីរុសកូរ៉ូណានៅតែបន្តបំប្លែងខ្លួនយ៉ាងសកម្មទៅជាប្រភេទថ្មីៗជាច្រើនដែលមានលទ្ធភាពចម្លងកាន់តែខ្ពស់ និង អាចបង្កហានិភ័យដល់សុខភាពសាធារណៈកាន់តែធ្ងន់ធ្ងរ ។ ការណ៍នេះ នឹងធ្វើឱ្យវិបត្តិជំងឺកូវីដ-១៩ នៅតែបន្តអូសបន្លាយ ជាមួយនឹងភាពមិនប្រាកដប្រជាខ្ពស់ ។ ដូច្នេះ, ចៀសមិនផុត, ដំណើរនៃការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ នឹងត្រូវធ្វើឡើងក្នុងបរិការណ៍នៃការ-រស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ។

សម្រាប់កម្ពុជា, ក្នុងឆ្នាំ ២០២០, សេដ្ឋកិច្ចជាតិសម្រេចបានកំណើនអវិជ្ជមាន ដែលពុំធ្លាប់មានពីមុនមក ដោយសារវិស័យជំរុញកំណើនសំខាន់ៗ រួមមាន វិស័យទេសចរណ៍ និង វិស័យគាំទ្រផ្សេងទៀត ដូចជា កាត់ដេរ, សំណង់ និង អចលនទ្រព្យ បានធ្លាក់យ៉ាងគំហុក ។ ជាការពិត, សេដ្ឋកិច្ចកម្ពុជាអាចនឹងមានកំណើនអវិជ្ជមានជ្រៅជាងនេះ ក្នុងករណីពុំមានការដាក់ចេញជាបន្តបន្ទាប់កន្លងមក នូវវិធានការអន្តរាគមន៍ទាន់ពេល និង ប្រកបដោយប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល ដែល, ម្ខាង, សំដៅជានាលំនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ, និងម្ខាងទៀត, សំដៅរក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជនដែលទទួលរងផលប៉ះពាល់ខ្លាំង ។ ជាមួយគ្នា, រាជរដ្ឋាភិបាលក៏បន្តខិតខំទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស តាមរយៈការអនុវត្តយុទ្ធសាស្ត្រវ៉ាក់សាំង ដែលឈរលើគោលការណ៍ជាក់ស្តែង-និយម និង ទន់ភ្លន់, ប៉ុន្តែ ម៉ឺងម៉ាត់ ព្រមទាំងបត់បែនទាន់ពេល ទៅតាមសភាពការណ៍តម្រូវ ។ ជាលទ្ធផល, រាជរដ្ឋាភិបាលសម្រេចបាននូវអត្រាចាក់វ៉ាក់សាំងជូនប្រជាជន ក្នុងកម្រិតមួយខ្ពស់ ធៀបនឹងប្រទេសផ្សេងទៀត, ទាំងក្នុងក្របខណ្ឌតំបន់ និង សកល, ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការឈានទៅសម្រេចបាននូវ "**ភាពស៊ាំសហគមន៍**" នៅក្នុងប្រទេស និង ដែលបានធ្វើឱ្យអត្រាឆ្លង ក៏ដូចជាអត្រាចូលសម្រាកពេទ្យ និង អត្រាមរណភាព មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ។ លើមូលដ្ឋាននេះ, ថ្មីៗនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវ "**យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩**" ជាមួយនឹងទស្សនវិស័យនៃការចាកចេញពី

វិបត្តិនៃជំងឺកូវីដ-១៩ ក្នុងភាពរឹងមាំ និង ការវិលត្រលប់ទៅរកមាគ៌ានៃកំណើន និង ការអភិវឌ្ឍប្រកបដោយចីរភាពឡើងវិញ ។

ជំណាលគ្នា, រាជរដ្ឋាភិបាលក៏បានគិតគូរផងដែរ អំពីការរៀបចំដាក់ចេញនូវយុទ្ធសាស្ត្រ និងកញ្ចប់នៃវិធានការគោលនយោបាយដើម្បីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា រួមបញ្ចូលទាំងការ-ចាប់យកកាលានុវត្តភាពថ្មីៗពីវិបត្តិនេះ ដោយផ្តោតជាចម្បងលើការកែទម្រង់ និង ការដោះស្រាយបញ្ហាប្រឈមសំខាន់ៗ, ទាំងក្នុងពេលចំពោះមុខ និង ទាំងក្នុងរយៈពេលមធ្យម, សំដៅលើកកម្ពស់បរិយាកាសវិនិយោគ និង បង្កើនភាពងាយស្រួលក្នុងការធ្វើធុរកិច្ច ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលរំពឹងយ៉ាងមុតមាំថា **"ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣",** ដែលត្រូវបានដាក់ចេញក្នុងពេលនេះ, នឹងដើរតួនាទីជាផែនទីបង្ហាញផ្លូវ និង ជាកម្លាំងចលករដ៏មានប្រសិទ្ធភាព សម្រាប់ការពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ឱ្យរស់រវើកឡើង ក៏ដូចជាសម្រាប់ការចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីដែលកំពុងលេចឡើង ស្របនឹងនិន្នាការតំបន់ និង សកល ដើម្បីលើកកម្ពស់កំណើនប្រកបដោយចីរភាព និង ដែលកាន់តែមានពិពិធកម្ម ក៏ដូចជាដើម្បីកសាងភាពធន់ដ៏រឹងមាំនៃសង្គម-សេដ្ឋកិច្ច ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** (គ.ស.ហ.), ក្នុងការដឹកនាំគណៈកម្មាធិការអន្តរក្រសួង-ស្ថាប័ន និង ក្រុមការងារបច្ចេកទេស ដើម្បីរៀបចំសម្រេចបាននូវឯកសារក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ ដ៏មានសារៈសំខាន់នេះឡើង យ៉ាងឆាប់ និង ទាន់ពេល ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមថ្លែងអំណរគុណ និង សម្តែងនូវការវាយតម្លៃខ្ពស់ ជូនដល់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ដែលជាថ្នាក់ដឹកនាំ និង តំណាងនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ព្រមទាំងក្រុមការងារនៃអគ្គលេខាធិការដ្ឋាន **គ.ស.ហ.** ចំពោះការចូលរួមយ៉ាងសកម្ម និង ប្រកបដោយការទទួលខុសត្រូវ ក្នុងការរៀបចំឯកសារនេះ ។

នៅចុងបញ្ចប់, ជាមួយនឹងការអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការ នូវ **"ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"** នេះ, ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់ក្រសួង-ស្ថាប័ន និង តួអង្គ ដែលមានការពាក់ព័ន្ធ ឱ្យសកម្មចូលរួមអនុវត្តបណ្តាវិធានការដែលមានចែងនៅក្នុងឯកសារនេះ ក្នុងឆន្ទៈមោះមុតប្រកបដោយស្មារតីទទួលខុសត្រូវ និង កិច្ចសហការខ្ពស់ សំដៅជានាសម្រេចបានជោគជ័យ និង លទ្ធផលជាក់ស្តែង តាមការរំពឹងទុក ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៤០......សហវ.......

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារចំពោះកិច្ចរៀបចំក្របខណ្ឌគតិយុត្តសម្រាប់ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធពីក្រសួង ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹតលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ ស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធាន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្ដីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត "**ក្រុមការងារចំពោះកិច្ចកម្រិតថ្នាក់ដឹកនាំរៀបចំក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធពីក្រសួង ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ**" ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ទង់ សណ្ដាប់** | រដ្ឋលេខាធិការ នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) | ប្រធាន |
| ២. | ឯកឧត្តម **យ៉េត ទីណែល** | អនុរដ្ឋលេខាធិការ នៃ កសហវ. និងជាអគ្គលេខាធិការរង នៃ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) | អនុប្រធាន |
| ៣. | ឯកឧត្តម **អូន ម៉ិនហាក់** | អគ្គនាយករង នៃ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) | អនុប្រធាន |
| ៤. | ឯកឧត្តម **នួន ទិត្យា** | អគ្គនាយករង នៃ អគ្គនាយកដ្ឋានរតនាគារជាតិ (អ.រ.ជ.) | សមាជិក |
| ៥. | បណ្ឌិត **គីម តែវមុនីរ័ត្ន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា (អ.ថ.) | សមាជិក |
| ៦. | លោក **សារឿន សុគុល** | អគ្គនាយករង នៃ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ (អ.ហ.ក) | សមាជិក |
| ៧. | លោក **ឈាន សាមឌី** | អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម (ល.ក.ន.) | សមាជិក |

**ប្រការ២ .-**

ក្រុមការងារចំពោះកិច្ចកម្រិតថ្នាក់ដឹកនាំ មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ដឹកនាំការរៀបចំក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកវិលែកចំណូលមិនមែនសារពើពន្ធពីក្រសួង ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន ក្របខណ្ឌរួម និងប្រកាសអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិនិត្យ និងសម្រេច
- ដឹកនាំកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួង-ស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធ ដើម្បីពិនិត្យសេចក្តីព្រាងក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកវិលែកចំណូលមិនមែនសារពើពន្ធពីក្រសួង ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ៣ .-**

សមាសភាពក្រុមការងារចំពោះកិច្ចកម្រិតថ្នាក់ដឹកនាំ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអាចដឹកនាំកិច្ចប្រជុំ និងដឹកនាំការងារជំនួសតាមការផ្ទេរសិទ្ធិរបស់ប្រធានក្រុមការងារ ។

**ប្រការ៤ .-**

ត្រូវបានបង្កើត **"ក្រុមការងារចំពោះកិច្ចកម្រិតបច្ចេកទេសរៀបចំក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកវិលែកចំណូលមិនមែនសារពើពន្ធពីក្រសួង ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ"** ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **យ៉េត ទីណែល** | អនុរដ្ឋលេខាធិការ នៃ កសហវ. និងជាអគ្គលេខាធិការរង នៃ អ.គ.ហ. | ប្រធាន |
| ២. | លោក **អ៊ុំ យុទ្ធី** | ប្រធានផ្នែក នៃ អ.គ.ហ. | អនុប្រធាន |
| ៣. | លោក **ម៉ៅ បុញ្ញខេត្ត** | ប្រធាននាយកដ្ឋាន នៃ អ.ទ.ច | អនុប្រធាន |
| ៤. | លោក **ជា ចន្ទ្រារ័ត្ន** | ប្រធាននាយកដ្ឋាន នៃ អ.រ.ជ. | សមាជិក |
| ៥. | លោក **អ៊ុក ចន្ថារ៉ា** | អនុប្រធាននាយកដ្ឋាន នៃ អ.រ.ជ. | សមាជិក |
| ៦. | លោក **លី សំអុល** | អនុប្រធាននាយកដ្ឋាន នៃ អ.ថ. | សមាជិក |
| ៧. | លោក **រស់ សីហា** | អនុប្រធាននាយកដ្ឋាន នៃ អ.ថ. | សមាជិក |
| ៨. | លោក **ហួយ ទិចិត្រ** | អនុប្រធាននាយកដ្ឋាន នៃ អ.ហ.ក. | សមាជិក |
| ៩. | លោក **គីម គុយម៉េង** | អនុប្រធាននាយកដ្ឋាន នៃ អ.ហ.ក. | សមាជិក |
| ១០. | លោក **ជា គឹមតុង** | អនុប្រធាននាយកដ្ឋាន នៃ អ.ទ.ច | សមាជិក |
| ១១. | លោក **ឆេព ចន្ថាដា** | អនុប្រធាននាយកដ្ឋាន នៃ អ.ទ.ច | សមាជិក |
| ១២. | លោក **ផាត ពិសី** | អនុប្រធាននាយកដ្ឋាន នៃ អ.ទ.ច | សមាជិក |

| | | |
|---|---|---|
| ១៣. លោក **លុន ម៉ារ៉ែត** | ប្រធានក្រុមជំនួយការរដ្ឋលេខាធិការ នៃ កសហវ. | សមាជិក |
| ១៤. លោក **ផល សុលី** | ប្រធានក្រុមជំនួយការអនុរដ្ឋលេខាធិការ នៃ កសហវ. | សមាជិក |
| ១៥. លោក **ទិបុល សីហបុត្រ** | ជំនួយការរដ្ឋលេខាធិការ នៃ កសហវ. | សមាជិក |
| ១៦. លោក **ហ៊ិត់ ឆានី** | ប្រធានការិយាល័យ នៃ អ.ទ.ច | សមាជិក |
| ១៧. លោកស្រី **ស្ងួន ពិនកាន្និកា** | ប្រធានការិយាល័យ នៃ អ.ទ.ច | សមាជិក |
| ១៨. លោក **គីក ប៊ូរ៉ាស៊ី** | ប្រធានការិយាល័យ នៃ អ.ទ.ច | សមាជិក |
| ១៩. លោកស្រី **ស៊ុម ចំន្ទសូរិយា** | អនុប្រធានការិយាល័យ នៃ អគ្គលេខាធិការដ្ឋាន កសហវ. | សមាជិក |
| ២០. លោកស្រី **រុន សោភា** | អនុប្រធានការិយាល័យ នៃ អ.រ.ជ. | សមាជិក |
| ២១. លោក **លី ទ៊ុង** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. | សមាជិក |
| ២២. លោក **អ៊ូច សោភ័ណា** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. | សមាជិក |
| ២៣. លោក **យន ម៉ាលីមរេង** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. | សមាជិក |
| ២៤. លោក **ឈុន ម៉ារឌី** | មន្ត្រីជំនាញ នៃ អ.គ.ហ. | សមាជិក |
| ២៥. លោក **ទុទ្ធី សត្រា** | មន្ត្រីជំនាញ នៃ អ.គ.ហ. | សមាជិក |
| ២៦. លោក **ជា សុខផេង** | មន្ត្រីជំនាញ នៃ អ.គ.ហ. | សមាជិក |
| ២៧. លោក **កាង ស៊ុង ឈាង** | មន្ត្រីជំនាញ នៃ អ.គ.ហ. | សមាជិក |
| ២៨. លោក **ស៊ុន គីមហេង** | មន្ត្រីជំនាញ នៃ អ.គ.ហ. | សមាជិក |
| ២៩. លោកស្រី **ឈឿន រចនី** | មន្ត្រីជំនាញ នៃ ល.ក.ន. | សមាជិក |
| ៣០. លោក **ឈឹម ចំន្ទដារ៉ូ** | មន្ត្រី នៃ អគ្គលេខាធិការដ្ឋាន កសហវ. | សមាជិក |
| ៣១. លោក **ផល និព្វដារិទ្ធ** | មន្ត្រី នៃ អ.ហ.ក. | សមាជិក |
| ៣២. លោកស្រី **អ៊ុង ទលក្ខទេវី** | ជំនួយការមន្ត្រីជំនាញ នៃ អ.គ.ហ. | សមាជិក |
| ៣៣. កញ្ញា **ឡេង ចាន់តួង** | ជំនួយការមន្ត្រីជំនាញ នៃ អ.គ.ហ. | សមាជិក |

**ប្រការ៥ ._**

ក្រុមការងារចំពោះកិច្ចកម្រិតបច្ចេកទេស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជាសេនាធិការបច្ចេកទេសជូនក្រុមការងារចំពោះកិច្ចកម្រិតថ្នាក់ដឹកនាំ
- រៀបចំផែនការសកម្មភាពជាក់លាក់ និងចុះសិក្សាអំពីបញ្ហាប្រឈមជាក់ស្តែងនៅតាមក្រសួង ស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធ និងអង្គភាពច្រកចេញចូលតែមួយ រាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក ខណ្ឌ ក្នុងករណីចាំបាច់ ដើម្បីជាធាតុចូលសម្រាប់រៀបចំក្របខណ្ឌគតិយុត្តឱ្យបានគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាព
- ដឹកនាំកិច្ចប្រជុំកម្រិតបច្ចេកទេសរវាងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធ ជាមួយតំណាងក្រសួងមហាផ្ទៃ តាមតម្រូវការចាំបាច់

- រៀបចំសេចក្តីព្រាងក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីក្រសួង ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដាក់ជូនក្រុមការងារចំពោះកិច្ចកម្រិតថ្នាក់ដឹកនាំ ពិនិត្យនិងសម្រេច
- សម្របសម្រួលកិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ជូនក្រុមការងារចំពោះកិច្ចកម្រិតថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានក្រុមការងារ និងតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ៦ .-**

សមាជិកក្រុមការងារចំពោះកិច្ចកម្រិតបច្ចេកទេស ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអាចដឹកនាំកិច្ចប្រជុំ និងដឹកនាំការងារជំនួសតាមការផ្ទេរសិទ្ធិរបស់ប្រធានក្រុមការងារ ។

**ប្រការ៧ .-**

ក្រុមការងារចំពោះកិច្ច កម្រិតថ្នាក់ដឹកនាំ និងកម្រិតបច្ចេកទេស នឹងត្រូវរំសាយ បន្ទាប់ពីក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីក្រសួង ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ។

**ប្រការ៨ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និង ប្រការ៤ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ថ្ងៃ... ខែ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ:.................................

ថ្ងៃ................ ខែ........ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៩.. ខែ........ ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបំបែកសង្កាត់ចោមចៅ នៃខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- យោងលិខិតលេខ១៨៨៣/១៥ គ.វ.ក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការស៊ុំវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតស្រាទឹកត្នោត-ស្ករត្នោត-ស្ករគ្រាប់-ម្រេចកញ្ចប់-ម្រេចជ្រក់ និងតែ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ខនហ្វីរេល

## <u>សម្រេច</u>

<u>**ប្រការ១៖**</u> អនុញ្ញាតឱ្យក្រុមហ៊ុន **ខនហ្វីរេល (CONFIREL CO., LTD.)** តំណាងដោយលោក **ហៃ លីអាង** សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ 010451083(01) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ បង្កើតរោងចក្រ**ផលិតស្រាទឹកត្នោត-ស្ករត្នោត-ស្ករគ្រាប់-ម្រេចកញ្ចប់-ម្រេចជ្រក់ និងតែ** ដែលមានទីតាំងស្ថិតនៅ**ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។**

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| **១- ស្រា (ពីទឹកត្នោត)** | **១១០២** |
| **២- ស្ករត្នោត, ស្ករគ្រាប់ (ពីទឹកត្នោត)** | **១០៧២** |
| **៣- ម្រេច (កញ្ចប់, ជ្រក់) និងតែ** | **១០៧៩** |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រផលិតស្រាទឹកត្នោត-ស្ករត្នោត-ស្ករគ្រាប់-ម្រេចកញ្ចប់-ម្រេចជ្រក់ និងតែ ខនហ្វីរេល "**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្ដីពី វិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ១៧២ ឧស.កឧ.ប្រក.០៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

ហាន សុគា

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលារាជធានីភ្នំពេញ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- -រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- -រដ្ឋបាលសង្កាត់ចោមចៅទី៣
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ............................................

ថ្ងៃ.................... ខែ.............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
